# ព្រះរាជាណាចក្រកម្ពុជា

**រាជរដ្ឋាភិបាលកម្ពុជា** **ជាតិ សាសនា ព្រះមហាក្សត្រ**

**លេខ:** ៣៨ សសរ

## សេចក្តីសម្រេច
## ស្តីពី
## ការកែសម្រួលសមាសភាពនៃក្រុមការងារសម្រាប់ធ្វើការសិក្សា អំពីគម្រោងបង្កើតពន្ធលើដី និងលំនៅដ្ឋាន នៅរាជធានីភ្នំពេញ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/ ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញសេចក្តីសម្រេចលេខ ៣៧ សសរ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការបង្កើតក្រុមការងារសម្រាប់ធ្វើការសិក្សា អំពីគម្រោងបង្កើតពន្ធលើដី និងលំនៅដ្ឋាននៅរាជធានីភ្នំពេញ
- យោងតាមការចាំបាច់នៃការងារ

## សម្រេច

**ប្រការ ១.-** ត្រូវបានកែសម្រួលសមាសភាពក្នុងប្រការ ១ នៃសេចក្តីសម្រេចលេខ ៣៧ សសរ ចុះថ្ងៃទី ០៧ ខែ កញ្ញា ឆ្នាំ ២០០៥ ស្តីពីការបង្កើតក្រុមការងារសម្រាប់ធ្វើការសិក្សាអំពីគម្រោងបង្កើតពន្ធលើដី និងលំនៅដ្ឋាននៅរាជធានីភ្នំពេញ ដោយបាត់បន្ថែម :

-លោក **សៀក វណ្ណា** ប្រធាននាយកដ្ឋានអភិរក្សសុរិយោដី ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក។

**ប្រការ ២.-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួងស្ថាប័នពាក់ព័ន្ធ អភិបាលរាជធានិភ្នំពេញ និងសាមីខ្លួន ក្នុងប្រការ ១ មានភារកិច្ចអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

*រាជធានីភ្នំពេញ ថ្ងៃទី ០៦ ខែ កញ្ញា ឆ្នាំ ២០០៥*

**ហ៊ុន សែន**

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចប្រការ ២
- ឯកសារ កាលប្បវត្តិ

change obeses.doc